ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២១២២ អជប

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ១០ ឆ្នាំ ២០១៦

សេចក្តីណែនាំ
ស្តីពីការប្រើប្រាស់លេខរៀងវិក្កយបត្រ
សម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធជារាងរបបស្វ័យប្រកាស

អនុលោមតាមអាត្រា៧៧ អាត្រា៧៨ និងអាត្រា៩៨ នៃស្តាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) ព្រមទាំងសេចក្តីណែនាំលេខ ១១២៧ អតប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធជារាងរបបស្វ័យប្រកាស អ្នកជាប់ពន្ធទាំងអស់ត្រូវចេញវិក្កយបត្រលើការលក់ ឬផ្តល់ផ្គត់ផ្គង់ទំនិញឬសេវា តាមតំរូវខ្លួនអាចភ្ជាប់ក្នុងនូវលក្ខខ័ណ្ឌនៃសេចក្តីណែនាំលេខ ១១២៧ អតប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ និងត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងនិងបានត្រឹមត្រូវ។

ក្នុងការពង្រឹងការគ្រប់គ្រងប្រមូលចំណូលសារពើពន្ធប្រកបដោយប្រសិទ្ធភាព ឥតភ្លាត់ និងធានាដល់យន្តការត្រួតពិនិត្យសារពើពន្ធ ឲ្យបានកាន់តែល្អាស់លាស់ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំអំពីការប្រើប្រាស់លេខរៀងវិក្កយបត្រ ដូចខាងក្រោម÷

ក. ត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងពេញមួយឆ្នាំ និងត្រូវរក្សាទុកជាឯកសារ សម្រាប់គោលដៅពន្ធដារ រយៈពេល ១០ ឆ្នាំ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ និងរយៈពេល ០៣ឆ្នាំ សម្រាប់អ្នកជាប់ពន្ធតូច

ខ. អ្នកជាប់ពន្ធអាចប្រើក្នុងអក្សរនៅពីមុខលេខលំដាប់វិក្កយបត្រ សម្រាប់សម្គាល់ទីកន្លែងចេញវិក្កយបត្ររបស់ការិយាល័យកណ្តាល (Head Office) ឬសាខាដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ និងត្រូវមានលំដាប់លេខរៀងវិក្កយបត្រតាមសណ្ឋិតដារតែមួយប៉ុណ្ណោះ (ឧទាហរណ៍÷ PPCI-0001, PPCI-0002, PPCI-0003,... និង PPTI-0001, PPTI-0002, PPTI-0003,... ឬ SRCI-0001, SRCI-0002, SRCI-0003,... និង SRTI-0001, SRTI-0002, SRTI-0003,...)។ ចំពោះអ្នកជាប់ពន្ធមានសាខាគឺត្រូវចេញនូវវិក្កយបត្រតាមសាខានីមួយៗ ដាច់ដោយឡែកពីគ្នា និងផ្សេងគ្នាពីការិយាល័យកណ្តាល (Head Office) ហើយត្រូវបែងចែកវិក្កយបត្រជាពីរនូវគឺវិក្កយបត្រអាករ (Tax Invoice) និងវិក្កយបត្រពាណិជ្ជកម្ម (Commercial Invoice)

គ. មិនអនុញ្ញាតឲ្យប្រើក្នុងអក្សរផ្សេងៗគ្នានៅពីមុខលេខលំដាប់នូវវិក្កយបត្រតែមួយ ក្នុងគោលដៅធ្វើការបែងចែកវិក្កយបត្រទៅតាមប្រភេទអតិថិជន តាមផលិតផល តាមតំបន់ តាមសកម្មភាព និងតាមប្រភេទផ្សេងៗទៀតឡើយ

ឃ. ចំពោះអ្នកជាប់ពន្ធដែលចេញវិក្កយបត្រតាមម៉ាស៊ីនគិតលុយ (POS) អ្នកជាប់ពន្ធអាចចេញលំដាប់លេខរៀងវិក្កយបត្រទៅតាមម៉ាស៊ីនតឹមួយៗបាន ប៉ុន្តែត្រូវតែលេខលេខសម្គាល់របស់ម៉ាស៊ីនលើវិក្កយបត្រនោះ ព្រមទាំងត្រូវភាពការណ៍ឲ្យបានត្រឹមត្រូវអំពីចំនួនម៉ាស៊ីន ត្រឹមដំណាច់ខែមករា ឆ្នាំ២០១៧ និងត្រូវជូនដំណឹងរាល់ការផ្លាស់ប្តូរម៉ាស៊ីន មកអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់ និងជាបណ្តាធិការ នៃសហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ បានយ៉ាងម្ចាស់ខ្លួនប្រកបដោយតម្លាភាព និងស្មារតីទទួលខុសត្រូវ ព្រមទាំងកិច្ចសហការ។

អ្នកនាំពាក្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានពន្ធដារ

ឈាង ទិបុល

អគារលេខ២០ ផ្លូវ២០០ សង្កាត់ទួលស្វាយព្រៃ១ ១១០ ០ ១ ១ ១